**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ : ០៤៤ សរហក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី ស្ថានភាពក្រោយបទឈប់បាញ់ គិតពីម៉ោង៦ល្ងាច ថ្ងៃទី២៩ ខែធ្នូ ដល់ម៉ោង១រសៀល ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥

គិតចាប់ពីម៉ោង៦ល្ងាច ថ្ងៃទី២៩ ខែធ្នូ ដល់ម៉ោង១រសៀល ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥នេះ **វីរយុទ្ធជនកម្ពុជា និងយោធាថៃ** បានអនុវត្តបទឈប់បាញ់ ធ្វើឱ្យស្ថានភាពស្ងប់ស្ងាត់ ស្របតាមសេចក្តីប្រកាសរួម នៃកិច្ចប្រជុំពិសេសលើកទី៣ គណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ (GBC) នៅច្រកព្រំដែនអន្តរជាតិព្រំ ខេត្តប៉ៃលិន នាថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥។

**១-ស្ថានភាពពលរដ្ឋភៀសសឹក៖** បើគិតពីម៉ោង៦ល្ងាច ថ្ងៃទី២៩ ខែធ្នូ ដល់ម៉ោង១រសៀលថ្ងៃនេះ មានជនភៀសសឹក **១.៣៨០នាក់** បានបន្តវិលត្រឡប់ទៅលំនៅឋានវិញ ដែលធ្វើឱ្យជនភៀសសឹកនៅសល់សរុបមានចំនួន ៥៩៥.៥៤៥នាក់ ក្នុងនោះស្ត្រី ៣១០.៨៤៤នាក់ និងកុមារ១៨៧.២៩២នាក់។

**២-ការបន្តបិទផ្អាក និងការដំណើរការឡើងវិញសេវាសាធារណៈជាមូលដ្ឋាន៖** របាយការណ៍បឋម **ខេត្តបន្ទាយមានជ័យ** មានសាលារៀន៣៣០កន្លែង (រដ្ឋ២៤៦ ឯកជន៨៤) មន្ទីរពេទ្យ/មណ្ឌលសុខភាព៤កន្លែងនៅបន្តបិទផ្អាក ចំណែក១៥ កន្លែងទៀតបានដំណើរការឡើងវិញ ខណៈរដ្ឋបាលនៅថ្នាក់ស្រុក និងឃុំ-សង្កាត់ មួយចំនួនបន្តបិទផ្អាក។ **ខេត្តព្រះវិហារ** មានសាលារៀន៦១កន្លែង និងមន្ទីរពេទ្យ/មណ្ឌលសុខភាព១៤កន្លែងនៅបន្តបិទផ្អាក ខណៈរដ្ឋបាលនៅថ្នាក់ស្រុក១ និងឃុំចំនួន៦ បានដំណើរការឡើងវិញ។ **ខេត្តឧត្តរមានជ័យ** មានសាលារៀន២៦០កន្លែង មន្ទីរពេទ្យ/មណ្ឌលសុខភាព១៦កន្លែង រដ្ឋបាលនៅថ្នាក់ខេត្ត១ ក្រុង-ស្រុក២ ឃុំ-សង្កាត់១០ និងប៉ុស្តិ៍នគរបាលរដ្ឋបាល១កន្លែងបានបន្តបិទផ្អាក ខណៈមន្ទីរពេទ្យ/មណ្ឌលសុខភាព២កន្លែង រដ្ឋបាលស្រុក៣ អង្គភាពកងកម្លាំងមានសមត្ថកិច្ច១០ រដ្ឋបាលឃុំ៩ និងប៉ុស្តិ៍នគរបាលរដ្ឋបាល១៨កន្លែងបានដំណើរការឡើងវិញ។ ចំពោះបណ្តាស្រុក នៃ**ខេត្តបាត់ដំបង** ដែលរងផលប៉ះពាល់ គឺគ្រប់សាលារៀន មន្ទីរពេទ្យ/មណ្ឌលសុខភាព និងស្ថាប័នផ្តល់សេវាសាធារណៈនានាទាំងស៊ីវិល និងកងកម្លាំងមានសមត្ថកិច្ច ដំណើរការឡើងវិញចាប់ពីថ្ងៃទី៣០ ខែធ្នូនេះ។ ដោយឡែក **ខេត្តកោះកុង** មានសាលារៀន៦៦កន្លែងបានបន្តបិទផ្អាក។

**៣-ផលប៉ះពាល់ និងការខូចខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖ គ្មានថ្មី។** គិតចាប់ពីថ្ងៃទី៧ ខែធ្នូមក **ការខូចខាតទ្រព្យសម្បត្តិឯកជន** សរុប រួមមាន ផ្ទះ១៦០ខ្នង អគារស៊ីវិលឯកជន៧ អគារស្នាក់នៅ/សណ្ឋាគារ៥ ស្ថានីយ៍ប្រេង១ រថយន្ត៣៣គ្រឿង ម៉ូតូ១គ្រឿង លានទិញដំឡូង១ អគារឃ្លាំងទំនិញ១ បង្គោលអង់តែនទូរសព្ទ២ ជង្រុកស្រូវ១ និងសត្វពាហនៈ/សត្វព្រៃ២ក្បាល។ **ការខូចខាតទ្រព្យសម្បត្តិសាធារណៈ** សរុប រួមមាន សាលារៀន៧ មណ្ឌលសុខភាព២ សំណង់អគារ១៤ វត្តអារាម៥ សាលាឆទាន១ រថយន្ត១គ្រឿង ប្រាសាទបុរាណ៤ ស្ពាន៥ ផ្សារ១ ផ្លូវ៣ និងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី១ទីតាំង។

**៤-កិច្ចអន្តរាគមន៍រៀបចំផ្ទះសំបែង និងភូមិករពលរដ្ឋភៀសសឹក៖** ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នពាក់ព័ន្ធ ព្រមទាំងរដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ-សង្កាត់ បានកំពុងបន្តយកចិត្តទុកដាក់ពិនិត្យ និងដោះស្រាយកិច្ចការអាទិភាពជាច្រើនទៀត ដើម្បីធានាការវិលមករកប្រក្រតីភាព នៃសេវាសាធារណៈជាមូលដ្ឋាននៅតាមបណ្តាក្រុង ស្រុក និងឃុំ-សង្កាត់ ជាពិសេសក្នុងខេត្តជាប់ព្រំដែនដែលបានបិទផ្អាកក្នុងរយៈកាលកន្លងមក។

ជាមួយគ្នានេះ ក៏បាននិងកំពុងខិតខំបង្កលក្ខណៈជូនជនភៀសសឹកឆាប់បានវិលត្រឡប់ទៅលំនៅឋានវិញប្រកបដោយសុវត្ថិភាព។ ក្នុងនោះរួមទាំងការដោះស្រាយបញ្ហាចំពោះមុខសម្រាប់ផ្ទះសំបែង និងភូមិករពលរដ្ឋដែលរងការខូចខាតការបោសសម្អាតយុទ្ធភណ្ឌមិនទាន់ផ្ទុះ ទន្ទឹមនឹង**ការពិនិត្យនិងបន្តហាមឃាត់ការបង្ហោះអាកាសយានគ្មានមនុស្សបើក (ដ្រូន)** គ្រប់ទីកន្លែង គ្រប់ពេលវេលា រហូតដល់មានការណែនាំថ្មី។

**៥-ករណីពលរដ្ឋស្លាប់ និងរបួស៖ គ្មានថ្មី**។ ដូច្នេះ គិតចាប់ពីថ្ងៃទី៧ ខែធ្នូ មកដល់ម៉ោង១រសៀលថ្ងៃនេះ មានពលរដ្ឋស្លាប់ចំនួន៣២នាក់ និងរបួសចំនួន៩៥នាក់។

ពាក់ព័ន្ធនឹងការវិវត្តចុងក្រោយក្នុងដំណើរស្វែងរកសន្តិភាព **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមប្រកាសគាំទ្រជំហរដ៏មោះមុត និងច្បាស់លាស់របស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ដែលបានគូសបញ្ជាក់ថា **ការអនុវត្តបទឈប់បាញ់ មិនមែនជាការចុះចាញ់ ឬយកបូរណភាពទឹកដី និងអធិបតេយ្យជាតិ ទៅដោះដូរយកសន្តិភាពនោះឡើយ**។ ផ្ទុយទៅវិញ គឺជាការតម្កល់ឧត្តមប្រយោជន៍ជាតិ និងសុខុមាលភាពប្រជាជនជាអាទិភាព តាមរយៈការប្រកាន់ខ្ជាប់ភាពចាស់ទុំផ្នែកនយោបាយ ក្នុងមាគ៌ាសន្តិវិធីស្របតាមច្បាប់អន្តរជាតិ ដើម្បីបញ្ចប់អរិភាពរវាងប្រទេសទាំងពីរ។ ជាងនេះទៅទៀត សូមជនរួមជាតិ ជឿជាក់លើរាជរដ្ឋាភិបាល រួបរួមស្មារតីជាតិខ្មែរតែមួយ និងត្រូវយកការលំបាកនេះធ្វើជាឱកាស ដើម្បីឱ្យខ្មែរគ្រប់រូបចេះពួតដៃគ្នាកសាងជាតិយើង ឱ្យកាន់តែរឹងមាំ និងកាន់តែប្រសើរឡើង។ ទន្ទឹមគ្នានេះ **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** មានអំណរសាទរយ៉ាងក្រៃលែងចំពោះលទ្ធផល នៃកិច្ចប្រជុំទ្វេភាគី-ត្រីភាគី នៅខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** សូមគោរពថ្លែងអំណរគុណ និងគាំទ្រយ៉ាងស្មោះស្ម័គ្រចំពោះ **សម្តេចតេជោ ហ៊ុន សែន** និង **សម្តេចធិបតី ហ៊ុន ម៉ាណែត** ដែលបានដាក់ចេញយុទ្ធសាស្ត្រការពារជាតិយ៉ាងត្រឹមត្រូវ ធ្វើឱ្យប្រជាជនកម្ពុជា ទាំងក្នុង និងក្រៅប្រទេស កាន់តែទទួលបានអារម្មណ៍កក់ក្តៅ ដែលមានប្រតិបត្តិករ គឺវីរយុទ្ធជនជួរមុខឈរជើងយ៉ាងរឹងមាំអង់អាចជាញជ័យ រយៈពេល**២០យប់ ២១ថ្ងៃ** ការពារអធិបតេយ្យជាតិ និងប្រជាជន។ **យើងទាំងអស់គ្នា សូមបន្ទន់កាយ សង្រួមចិត្ត គោរពវិញ្ញាណក្ខន្ធវីរយុទ្ធជនពលី និងសូមចូលរួមទទួលអារម្មណ៍ឈឺចាប់ និងក្តីមោទនជាមួយក្រុមគ្រួសារ**។ យើងក៏សូមជូនពរវីរយុទ្ធជន ដែលកំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យឆាប់បានជាសះស្បើយ។ សូមជនរួមជាតិ បន្តស្មារតីព្រលឹងខ្មែរតែមួយជានិរន្តរ៍រៀងទៅ៕

ថ្ងៃអង្គារ ១១កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥